រាជធានីភ្នំពេញ,ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០០០

**សេចក្តីសំរេច លេខ ៥៤ សសរ**

**ស្តីពី**

**ការផ្ទេរសិទ្ធិ នៃរាជរដ្ឋាភិបាល**

***

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

**សំរេច**

ប្រការ ១ : ផ្ទេរសិទ្ធិជូនឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជានាយករដ្ឋមន្ត្រីស្តីទី នៃរាជរដ្ឋាភិបាលកម្ពុជា ជំនួសសម្តេចនាយករដ្ឋមន្ត្រី ដែលត្រូវអញ្ជើញទៅបំពេញទស្សនកិច្ចជាផ្លូវការនៅសាធារណរដ្ឋហ្វីលីពីន និងប្រទេសប្រ៊ុយណេ ដារុសាឡឹម ចាប់ពីថ្ងៃទី១៦ ខែសីហា ឆ្នាំ២០០០ រហូតដល់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាអញ្ជើញវិលត្រឡប់មកកាន់មាតុប្រទេសវិញ ។

ប្រការ ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នរាជរដ្ឋាភិបាល ប្រតិភូរាជរដ្ឋាភិបាល អភិបាលខេត្ត-ក្រុង និងឯកឧត្តម ស ខេង ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**នាយករដ្ឋមន្ត្រី**

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

***